# ព្រះពរគ្រប់យ៉ាងរបស់អ្នកជឿព្រះ THE BLESSINGS OF THE CHRISTIAN

*ម៉ាថាយ Matthew 5:1-12*

១ កាលបានឃើញហ្វូងមនុស្ស ទ្រង់ក៏យាងឡើងទៅលើភ្នំ រួចកាល
បានគង់ចុះហើយ នោះពួកសិស្សចូលមកឯទ្រង់ ២ ហើយទ្រង់បើក
ព្រះឱស្ឋបង្រៀនគេថា ៣ មានពរហើយ អស់អ្នកដែលមានសេចក្ដី
កំសត់ខាងឯវិញ្ញាណ ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ
៤ មានពរហើយ អស់អ្នកដែលយំសោក ដ្បិតអ្នកទាំងនោះនឹងបាន
សេចក្ដីកំសាន្តចិត្ត ៥ មានពរហើយ អស់អ្នកដែលស្លូតត្រង់ ដ្បិត
អ្នកទាំងនោះនឹងគ្រងផែនដីជាមរដក ៦ មានពរហើយ អស់អ្នក
ដែលស្រេកឃ្លាននូវសេចក្ដីសុចរិត ដ្បិតអ្នកទាំងនោះនឹងបានឆ្អែត
៧ មានពរហើយ អស់អ្នកដែលមានចិត្តមេត្តាករុណា ដ្បិតអ្នកទាំង
នោះនឹងបានសេចក្ដីមេត្តាករុណាវិញ ៨ មានពរហើយ អស់អ្នក
ដែលមានចិត្តបរិសុទ្ធ ដ្បិតអ្នកទាំងនោះនឹងបានឃើញព្រះ ៩ មាន
ពរហើយ អស់អ្នកដែលផ្សះផ្សាគេ ដ្បិតអ្នកទាំងនោះនឹងបានហៅ
ជាកូនរបស់ព្រះ ១០ មានពរហើយ អស់អ្នកដែលត្រូវគេបៀតបៀន
ដោយព្រោះសេចក្ដីសុចរិត ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នក
ទាំងនោះ ១១ អ្នករាល់គ្នាមានពរ ក្នុងកាលដែលគេជេរ
បៀតបៀន ហើយនិយាយបង្ខុសគ្រប់ទាំងសេចក្ដីអាក្រក់ ពីអ្នក
រាល់គ្នា ដោយព្រោះខ្ញុំ ១២ ចូរមានចិត្តអំណរ ហើយរីករាយជា

*ខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅឯស្ថានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នា បែបដូច្នោះដែរ។*

**អ្នកដែលកំសត់ខាងវិញ្ញាណ** The poor in spirit (Matthew 5:3)

**អ្នកដែលយំសោក** Those who mourn (Matthew 5:4)

**អ្នកដែលស្លូតត្រង់** The meek (Matthew 5:5)

**អ្នកដែលស្រេកឃ្លាននូវសេចក្តីសុចរិត**

Hungering and thirsting after righteousness (Matthew 5:6)

**អ្នកដែលមានចិត្តបរិសុទ្ធ** The pure in heart (Matthew 5:8)

**អ្នកដែលផ្សះផ្សារគេ** Peacemakers (Matthew 5:9)

**អ្នកដែលគេជេរបៀតបៀន** Persecution (Matthew 5:10-12)